**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងព្រហ្មទណ្ឌលេខៈ ១០១៣ អ.ក
ចុះថ្ងៃទី២៨-មិថុនា-២០២១
សាលក្រមលេខៈ ៥៦ (ន)
ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង០៩ព្រឹក ដោយមានសមាសភាពដូចតទៅ÷

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តកណ្តាល

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១០១៣ អ.ក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ÷ ឈ្មោះ [redacted] ម៉ុល ភេទស្រី អាយុ៦៣ឆ្នាំ សញ្ជាតិខ្មែរ មុខរបរលក់ដូរធ្វើចំការ ទីកន្លែងកំណើត [redacted] ខេត្តកណ្តាល និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] យុត (ស្លាប់) ម្តាយឈ្មោះ [redacted] លន់ (ស្លាប់) ប្តីឈ្មោះ [redacted] សុខ (ស្លាប់) មានកូនចំនួន០៥នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

-ជាប់ចោទពីបទៈ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ាស៊ី ភេទស្រី អាយុ៦០ឆ្នាំ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ២ សង្កាត់បឹងកេងកងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

-លោកស្រីមេធាវី [redacted] និងលោកស្រីមេធាវី [redacted] ក្រុមមេធាវីអាស៊ានមេគង្គ ការិយាល័យផ្ទះលេខ១០ដេ៦ ផ្លូវលេខ២១១ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៨៨០ ដកសព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ០៩២ ដកដស ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ០៩៤ ដកចត/២២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។



Scanned with CamScanner

## អង្គហេតុមានដូចតទៅ

-កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង០៨ និង១៥នាទី ស្ថិតនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានជនសង្ស័យឈ្មោះ ញ៉ែម ម៉ុល បានយកពូថៅទៅវាយរបងថ្មរបស់ឈ្មោះ [redacted]រ៉ាស៊ី បណ្ដាលឱ្យខូចខាតអស់ ដែលមានបណ្ដោយប្រវែង០២ម៉ែត្រ និងកម្ពស់១,៤០ម៉ែត្រ ពេលនោះមានឈ្មោះ[redacted]រុទ្ធី បានទូរស័ព្ទមកប្រាប់ឈ្មោះ[redacted]រ៉ាស៊ី ក្រោយមកឈ្មោះ[redacted]រ៉ាស៊ី បានមកឃើញមានការខូចខាតពិតមែន ក៏បានដាក់ពាក្យបណ្ដឹងទៅសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលគគីរ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

## ពេលសវនាការ

-អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ម៉ុល ចំពោះមុខចៅក្រមស៊ើបសួរ បានឆ្លើយបញ្ជាក់ថាៈ នៅថ្ងៃខែមិនចាំ ឆ្នាំ២០២១ វេលាម៉ោង០៨ព្រឹក ខ្លួនពិតជាបានវាយរបងថ្ម បណ្ដោយ០២ម៉ែត្រ ដោយវាយអស់ ១,៤ម៉ែត្រ និងកម្ពស់ ១,៤០ម៉ែត្រ គឺខ្លួនបានវាយរបងខ្លួន និងរបស់ឈ្មោះ [redacted]ឡុង ចំពោះរបងរបស់ឈ្មោះ [redacted] រ៉ាស៊ី ខ្លួនមិនបានវាយនោះទេ។ ចំពោះការវាយរបងថ្មនេះ គឺខ្លួនធ្វើឡើងក្នុងគោលបំណងចេញទៅឃាត់ឈ្មោះ [redacted]ឡុង មិនឱ្យធ្វើរបងទៀត និងចំពោះ[redacted]រ៉ាស៊ី មានដីនៅខាងក្រោយផ្ទះខ្លួនប្រហែល៦០ម៉ែត្រ ហើយដីរបស់ឈ្មោះ [redacted]រ៉ាស៊ី មិននៅជាប់ជាមួយដីរបស់ខ្លួននោះទេ គឺដីរបស់នាងនៅជាប់ជាមួយឈ្មោះ [redacted] ឡុង។

-អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted]រ៉ាស៊ី បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០៨ និង១៥នាទី ប្អូនស្រីបង្កើតរបស់ខ្លួនឈ្មោះ [redacted]រុទ្ធី មានទីលំនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល បានទូរស័ព្ទមកប្រាប់ខ្លួនថា របងរបស់ឯងត្រូវបានឈ្មោះ [redacted] ម៉ុល យកពូថៅមកវាយបាក់មួយប្រឡោះហើយ ឮដូច្នេះខ្លួន និងប្អូនប្រុសបានជិះឡានពីភ្នំពេញមកមើល។ ពេលមកដល់ដីចំការ ស្ថិតនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ហើយខ្លួន និងប្អូនប្រុសបានដើរទៅមើលកន្លែងដែលប្អូនស្រីរបស់ខ្លួន ប្រាប់ថាមានគេវាយនោះ ក៏ឃើញថារបងថ្មបានបាក់អស់ចំនួនមួយប្រលោះមែនកម្ពស់០២ម៉ែត្រ និងបណ្ដោយ០២ម៉ែត្រ ត្រូវបានឈ្មោះ [redacted] ម៉ុល វាយបាក់អស់។

-អំណានចម្លើយសាក្សីឈ្មោះ [redacted] រុទ្ធី បានឆ្លើយបញ្ជាក់ថាៈ កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០៧ និង០០នាទី ខ្លួនកំពុងបង្រៀនសិស្សតាមអនឡាញនៅផ្ទះ ស្រាប់តែបានឮសម្លេងគេវាយរបងថ្ម។ ពេលនោះខ្លួនក៏បានទៅមើលក៏បានឃើញឈ្មោះ [redacted] ម៉ុល កំពុងយកពូថៅមកវាយរបងថ្មរបស់បងស្រីរបស់ខ្លួនឈ្មោះ[redacted]រ៉ាស៊ី ពេលនោះខ្លួនក៏បានយកទូរស័ព្ទរបស់ខ្លួនមកថតពីសកម្មភាពរបស់ឈ្មោះ [redacted] ម៉ុល និងបានទូរស័ព្ទទៅប្រាប់បងស្រីរបស់ខ្លួនឈ្មោះ[redacted]រ៉ាស៊ី នៅភ្នំពេញ។ រហូតដល់ម៉ោង១០ និង១០នាទី បងស្រីរបស់ខ្លួនឈ្មោះ[redacted]រ៉ាស៊ី បានមកដល់ក៏បានដើរទៅមើលកន្លែងកើតហេតុ និងដាក់ពាក្យបណ្ដឹងទៅប៉ុស្តិ៍នគរបាលរដ្ឋបាលគគីរតែម្ដង។

-ក្រឡាបញ្ជីអានឯកនានានៅក្នុងសំណុំរឿងនេះ។

## សិទ្ធិនិយាយស្ដីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល

-មេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ាស៊ី បានសន្និដ្ឋានថាៈ ជនជាប់ចោទពិតជាប្រព្រឹត្តដូចការចោទប្រកាន់មែន ដូច្នេះស្នើសុំឱ្យតុលាការជនជាប់ចោទឱ្យបានធ្ងន់, ស្នើសុំឱ្យចេញដីកាចាប់ខ្លួន និងសងសំណងការខូចខាត ជម្ងឺចិត្ត ចំនួន ៤០,០០០,០០០(សែសិបលានរៀល)។

-តំណាងអយ្យការបានសន្និដ្ឋានថាៈ សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៨៨០ ដកសព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ទុកជាការបានដដែល និងសុំឱ្យតុលាការផ្ដន្ទាទោសជនជាប់ចោទតាមច្បាប់។



Scanned with CamScanner

## ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ុល។
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ាស៊ី។
-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] វុទ្ធី។
-ក្រោយពីបានស្តាប់ការអានឯកសារនានា។
-ក្រោយពីបានពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី។
-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។
-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់។

## សំអាងហេតុ

## តុលាការយល់ឃើញថា

១- កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០៨ និង១៥នាទី មានករណី **ធ្វើឱ្យខូចខាតដោយចេតនា** បង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ម៉ុល ដែលប្រព្រឹត្តនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល ពិតប្រាកដមែន។

២- តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] ម៉ុល ចំពោះមុខចៅក្រមស៊ើបសួរ បានឆ្លើយបញ្ជាក់ថាៈ នៅថ្ងៃខែមិនចាំ ឆ្នាំ២០២១ វេលាម៉ោង០៨ព្រឹក ខ្លួនពិតជាបានវាយរបងថ្ម បណ្តោយ០២ម៉ែត្រ ដោយវាយអស់ ១,៤ម៉ែត្រ និងកម្ពស់ ១,៤០ម៉ែត្រ ប្រាកដមែន។ ចម្លើយសារភាពនេះ មានលក្ខណៈស៊ីចង្វាក់ទៅនឹងចម្លើយដើមបណ្តឹងរដ្ឋប្បវេណី, ចម្លើយសាក្សីឈ្មោះ [redacted] វុទ្ធី និងស៊ីចង្វាក់ទៅនឹងភស្តុតាង ឯកសារគតិយុត្តនានាដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់បានថា កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ វេលាម៉ោង០៨ និង១៥នាទី ជនជាប់ចោទឈ្មោះ [redacted] ម៉ុល ពិតជាបានយកញញួរទៅវាយរបងថ្មរបស់ឈ្មោះ [redacted] រ៉ាស៊ី បណ្តាលឱ្យខូចខាត ពិតប្រាកដមែន។

៣- ជនជាប់ចោទ បានបញ្ជាក់ថា ខ្លួនវាយរបងថ្មនេះ ជារបងខ្លួន និងឈ្មោះ [redacted] ឡុង ដែលបានធ្វើរួមគ្នា។ ចំណែកដីរបស់ឈ្មោះ [redacted] រ៉ាស៊ី នៅខាងក្រោយដីខ្លួនចម្ងាយ ៦០ម៉ែត្រ មិនជាប់ដីខ្លួនទេ ដីខ្លួនជាប់ជាមួយឈ្មោះ [redacted] ឡុង។ តុលាការពិចារណាឃើញថាៈ ជនជាប់ចោទ មិនមានភស្តុតាងណាបង្ហាញថារបងថ្មនេះធ្វើរួមគ្នាជាមួយឈ្មោះ [redacted] ឡុង នោះទេ។ ចំពោះឈ្មោះ [redacted] ឡុង គឺជាប្តីរបស់ឈ្មោះ [redacted] រ៉ាស៊ី បើផ្អែកតាមសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍លេខៈ ៤៩ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២។ ដូច្នេះរបងនេះ គឺជាទ្រព្យសម្បត្តិរួមធ្វើឡើងដោយឈ្មោះ [redacted] ឡុង និងឈ្មោះ [redacted] រ៉ាស៊ី។ យោងតាមកំណត់ហេតុពិនិត្យ និងវិភាគកន្លែងកើតហេតុ ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២១ របស់មន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់ថា ឈ្មោះ [redacted] ម៉ុល ពិតជាបានវាយរបងរបស់ឈ្មោះ [redacted] រ៉ាស៊ី បណ្តាលឱ្យខូចខាត ប្រវែង១,៤០ម៉ែត្រ និងកម្ពស់០២ម៉ែត្រ ប្រាកដមែន។

៤- តាមរបាយការណ៍សរុបលេខ ៣៣៥ ០៤ ខែមិថុនា ឆ្នាំ២០២១ បញ្ជាក់បានថាៈ ឈ្មោះ [redacted] ម៉ុល ពិតជាបានយកញញួរ ទៅវាយរបងផ្ទះ ដែលមានបណ្តោយ០២ម៉ែត្រ និងកម្ពស់១,៤០ម៉ែត្រ របស់ឈ្មោះ [redacted] រ៉ាស៊ី ពិតប្រាកដមែន។

៥- តាមកំណត់ហេតុ ចុះពិនិត្យ និងវិភាគកន្លែងកើតហេតុ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២២ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលគគីរ ពិនិត្យឃើញកន្លែងកើតហេតុស្ថិតនៅក្នុងដីឡូ របស់ជនរងគ្រោះឈ្មោះ [redacted]ស៊ី ភេទស្រី អាយុ៦០ឆ្នាំ មុខរបរកសិករ ចម្ងាយពីផ្លូវជាតិលេខ១ ចំនួន២៥ម៉ែត្រ និងចម្ងាយពីរបងផ្ទះជនបង្កចំនួន០៣ម៉ែត្រ ដោយសម្ភារៈខូចខាតដូចជាៈ របងថ្ម មានកម្ពស់០២ម៉ែត្រ និងបណ្តោយ០២ម៉ែត្រ ប៉ុន្តែរបងខូចខាតអស់១,៤០ម៉ែត្រ និងកម្ទេចឥដ្ឋតូចធំធ្លាក់ពេញនៅលើដី។

៦- តាមកំណត់ហេតុស្វែងរកវត្ថុតាង លេខៈ ០៣២/២១ របស់មន្ត្រីនគរបាលយុត្តិធម៌ស្រុកកៀនស្វាយ ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១ រួមមានៈ ពូថៅចំនួនមួយ ដែលជាមធ្យោបាយប្រព្រឹត្តបទល្មើស។ ក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទ បានបោះពូថៅចោល មិនដឹងនៅកន្លែងណានោះទេ។

៧- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ម៉ុល មានចេតនាទុច្ចរិត ដោយបានវាយបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតនូវទ្រព្យសម្បត្តិរបស់អ្នកដទៃ គឺជាបទល្មើសព្រហ្មទណ្ឌបទៈ **ធ្វើឱ្យខូចខាតដោយចេតនា** បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤១០** នៃក្រមព្រហ្មទណ្ឌ។

៨- តំណាងអយ្យការបានប្តឹងសុំឱ្យតុលាការតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខៈ ១៨៨០ ដកសព ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២១ ទុកជាការបានដដែល និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថាមានលក្ខណៈត្រឹមត្រូវ តុលាការនឹងពិចារណាចំពោះការប្តឹងសុំនេះ។

៩- មេធាវីតំណាងដោយអាណត្តិ និងការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស៊ី បានធ្វើសេចក្តីសន្និដ្ឋានថាៈ ជនជាប់ចោទពិតជាបាន ប្រព្រឹត្តដូចការចោទប្រកាន់មែន ដូច្នេះស្នើសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទឱ្យបានធ្ងន់, ស្នើសុំឱ្យចេញដីកាចាប់ខ្លួន និងសងសំណងការខូចខាត និង ជម្ងឺចិត្ត ចំនួន ៤០,០០០,០០០ (សែសិបលានរៀល)។ តុលាការ និងពិចារណា ចំពោះការស្នើសុំនេះ។

១០- ជនជាប់ចោទឈ្មោះ [redacted] ម៉ុល ជានីតិជន មានស្មារតី និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចទទួលខុសត្រូវអំពើប្រព្រឹត្តរបស់ខ្លួន។

១១- ក្រោយពីបានពិនិត្យ នឹងពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើ÷ ឈ្មោះ [redacted] ម៉ុល ពីបទៈ **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៤១០** នៃក្រមព្រហ្មទណ្ឌ។

១២- អំពើប្រព្រឹត្តឈ្មោះ [redacted] ម៉ុល បានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម និងច្បាប់របស់រដ្ឋ។

១៣- ពេលសវនាការ មេធាវីតំណាងដោយអាណត្តិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ស៊ី បានទាមទារសំណងខូចខាត និងជម្ងឺចិត្ត ជាទឹកប្រាក់ចំនួន ៤០,០០០,០០០ (សែសិបលានរៀល)។ ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ប៉ុន្តែការទាមទារមានចំនួនច្រើនពេក គប្បីតុលាការសម្រេចឱ្យជនជាប់ចោទ បង់តាមសភាពជាក់ស្តែង និងសមហេតុផល។

Scanned with CamScanner

# សេចក្តីសម្រេច

១- ផ្តន្ទាទោស÷ ឈ្មោះ [redacted] ម៉ុល ភេទស្រី អាយុ៦៣ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ)ខែ។

ពីបទ: **ធ្វើឱ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិទួលក្របៅ ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល កាលពីថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។

២- បង្គាប់ឱ្យឈ្មោះ [redacted] ម៉ុល សងសំណងការខូចខាត និងជម្ងឺចិត្ត ចំនួន ៥,០០០,០០០(ប្រាំលានរៀល) ទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ាស៊ី។ បណ្តឹងទាមទារលើសពីនេះច្រានចោល តាមមាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ឈ្មោះ [redacted] ម៉ុល និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] រ៉ាស៊ី។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

**ហត្ថលេខា និងត្រា:** [redacted]

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា:** [redacted]

---

**បានឃើញ**

កណ្តាល, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

**ចៅក្រមជំនុំជម្រះ**

[redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ៥កើត ខែចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្តាល, ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២

**ក្រឡាបញ្ជីសវនាការ**

[redacted]



Scanned with CamScanner